វិបត្តិ នៃ លទ្ធិប្រជាធិបតេយ្យសេរី

ក្រោយពី របបកុម្មុយនិស្ត រលំបន្តបន្ទាប់គ្នា ចាប់ពីឆ្នាំ ១៩៨៩ នៅអឺរ៉ុបខាងកើត ដែលមាន ដំណួល នៃរបងទីក្រុង Berlin ជា និមិត្តរូប នៃ ជ័យជំនះ នៃ លទ្ធិប្រជាធិបតេយ្យសេរី ហើយនិង និទាឃរដូវ អារ៉ាប់ ចាប់ពីឆ្នាំ ២០១០ ដែលជា ចលនា នៃវ៉ាទ កម្ម របស់ប្រជាជន នាំឲដួល នូវរបបផ្តាច់ការមួយចំនួន, វា ហាក់បីដូចជា ពិភពលោក បំភ្លឺដោយរស្មី នូវសេរីភាព និង សិទ្ធិ នៃប្រជាពលរដ្ឋ អាចសម្រេចលើជោគវាសនារបស់ខ្លួនឯង។ ដូចលោក Francis Fukuyama សរសេរ ក្នុងសៀវភៅពិសេស[1] របស់លោក ថា ‹ដំណាច់ នៃ ប្រវត្តិសាស្ត្រ› គឺជា ជ័យជំនះ នៃ របបដឹកនាំ នៃលទ្ធិប្រជាធិតេយ្យសេរី នៅក្នុងភពលោក។

ជាការពិត នៅក្នុង ដលោកនេះ វាមានប្រទេសតិចណាស់ ដែល ដឹកនាំដោយ របបកុម្មុយនិស្ត និង របបផ្តាច់ការ មួយចំនួន។ តែនៅលើចំណុចមួយ ដែល លទ្ធិប្រជាធិបតេយ្យសេរី មិនទាន់ ដោះស្រាយបាននៅឡើយ គឺ ទំនាក់ទំនង ដ៏ពិបាកមួយ រវាង លទ្ធិប្រជាធិបតេយ្យសេរី នឹង ចំណង់ឲគេទទួលស្គាល់ខ្លួន[2]។ ក្នុងរយៈពេលវែងមួយ លទ្ធិប្រជាធិបតេយ្យសេរី វាអាចបង្ហូច ពី

[1] La fin de l'histoire et le dernier homme – édition Flammarion 1992.

[2] Désir de reconnaissance.

ខាងក្នុង, ឬក៏មកពី ឆ្លួតយស លើសលន់[3], ឬក៏មកពី ឆ្លួតយស អន្ទះអន្ទែង ស្រេបច្បាប់[4]។ តាមលោក Fukuyama ឆ្លួតយស ទី១ គឺជាគ្រោះថ្នាក់ធំ ដល់លទ្ធិប្រជាធិបតេយ្យសេរី។ ចំណែក អារ្យធ ម៌ណា ដែលជំរុញ ឲមាន ឆ្លួតយស ស្រេបច្បាប់ គ្មានអ្វីទប់ទល់ ហើយ ស្វែងរកដោយអន្ទះអន្ទែង នូវការលុបបំបាត់ នៃ គ្រប់ ការសំដែង នៃការទទួលស្គាល់ ក្រៅច្បាប់ វានឹងប្រឆាំងនាប់ នឹង ដែនកំណត់ខ្លួនឯង តាមច្បាប់ធម្មជាតិ។ ដូចយ៉ាង របប កុម្មុយនិស្ត បានប្រើរយ:ពេលដ៏យូរអង្វែង តែស្រកោក[5] ស្វែង បង្កើត នូវ សង្គមគ្មានវណ្ណ: ដោយប្រើអំណាចរដ្ឋ ដើម្បី លុប បំបាត់នូវអ្វីគ្រប់បែបយ៉ាងដែលអង្គការបក្ស មិនទទួលស្គាល់។ ឧទាហរណ៍ : លុបបំបាត់ នូវ រូបអាក្រក់ និង រូបល្អ ក្នុងនាម នៃ សមភាពដាច់ខាត ទទួលស្គាល់ដោយច្បាប់កំពូល របស់អង្គការ បក្ស ព្រោះវាជាច្បាប់ ប្រសើរដាច់ខាត។ ដូចយ៉ាង ពន្យល់ កូន ឲអាចសម្លាប់មាតាបិតា ព្រោះ វាជា ពលកម្ម ដ៏ខ្ពង់ខ្ពស់ សំរាប់ បំរើ ប្រយោជន៍ ដល់ បដិវត្តន៍ នៃបក្ស។ ការណ៍ទាំងនេះ ទុកជា ឆ្លួតយសស្រេបច្បាប់ របស់បក្ស ដែលនៅទីបញ្ចប់ វានាំ បក្ស ឲ រលំរលាយ ព្រោះវា ជា ឆ្លួត ប្រឆាំងនឹងច្បាប់ធម្មជាតិ។

តែ គ្រោះថ្នាក់ខ្លាំង គឺ ឆ្លួតលើសលាន់ ព្រោះវាជា ឆ្លួត មាននៅ ក្នុងធាតុមនុស្ស តែម្តង។ ទោះបី តម្លៃ នៃមនុស្ស ត្រូវបានគេ

---

[3] ឆ្លួតយស លើសលន់; mégalothymia។
[4] ឆ្លួតយស អន្ទះអន្ទែង ស្រេបច្បាប់ ; isothymia។
[5] ស្រកោក, មិនបានសម្រេច, គ្មានប្រយោជន៍។

វិបត្តិ នៃ លទ្ធិប្រជាធិបតេយ្យសេរី

ទទួលស្គាល់ជាសាកល តាមការប្រកាសជាឧឡារិក ក្នុងធម្មនុញ្ញ នៃ អង្គការសហប្រជាជាតិ ក្រោយពីមាន ការប្រយុទ្ធប្រឡាក់ឈាម ដ៏យូរមួយ នៅក្នុងប្រវត្តិសាស្ត្រ នៃមនុស្សជាតិ តែ សេចក្តីប្រាថ្នា ជាសារវន្ត នៃមនុស្ស វានៅមានដដែល គឺ ចំណង់ឲគេទទួលស្គាល់ខ្លួន។ នៅក្នុង ប្រទេស មហទ្ធន ទោះបីបានរំលាយបាន ជាគោលការណ៍ នូវ សេចក្តីត្រូវការ ជាធម្មជាតិ តែនៅមានពលរដ្ឋមួយចំនួនធំ នៅខ្វះនៅឡើយ នូវ ម្ហូបចំណី, ជម្រក និង សេចក្តីត្រូវការចាំបាច់ ជាធម្មជាតិ ផ្សេងៗទៀត សំរាប់រស់នៅ ដែលជាចំណោទសំខាន់ ដល់ប្រទេសប្រជាធិបតេយ្យលុះមុខ ត្រូវដោះស្រាយ។ តែ គេឃើញថា ដំណោះស្រាយ វាច្រើន តែ រិះរក នូវ សុខុមាលភាព ជាង សក្តិយស នៃ ជនក្រីក្រ ដែលជាដំណោះស្រាយ មិនឆ្លើយចំ នូវ សេចក្តីប្រាថ្នា ជាសារវន្ត នៃ មនុស្ស គឺ ចំណង់ឲគេទទួលស្គាល់ខ្លួន នោះឯង។ ដូច្នេះ នៅ ក្នុងសង្គម ដែលនៅតែមាន ជនក្រីក្រ និង ជនមានទ្រព្យា គឺ នៅមានជានិច្ច នូវបញ្ហា សក្តិយស នៃមនុស្ស ដែលអ្នកខ្លះ ទុកជា បញ្ហាធម្មតា នៃសង្គម តែអ្នកខ្លះទៀត ទុកជា បញ្ហា ទាបថោក នៃមនុស្សជាតិ។ តែវាគ្មាន ហាន:ដាច់ខាត នៃ វិបុលភាព សម្ភារ: ណាមួយ ដែលអាចនឹងទូទាត់ នូវការប្រមាថរាល់ថ្ងៃ ដល់ សក្តិយស នៃជនក្រីក្រ នោះបានឡើយ។ ជាថ្មីម្តងទៀត បញ្ហាសំខាន់ ដល់ លទ្ធិប្រជាធិបតេយ្យសេរី គឺ រិះរក នូវសមតាភ្ជួតយសនោះឯង ដែលអាចបង្កើត នូវវិបត្តិផ្ទៃក្នុង នៃខ្លួន។ ត្រូវដឹងថា អ្វីដែលកើតមានដល់ លទ្ធិកុម្មុយនិស្ត នៅទស្សវត្ស៍

វិបត្តិ នៃ លទ្ធិប្រជាធិបតេយ្យសេរី

៨០-៩០ ក៏នឹងអាចកើតមានដែរដល់ លទ្ធិប្រជាធិបតេយ្យសេរី នៅថ្ងៃណាមួយ ក្រោមអនុភាព នៃ ភាពពុករលួយ ផ្សេងៗ និង ជំហរ ធ្ងរលុង នៃខ្លួន ក្នុងការការពារ ប្រឆាំងនឹង ការ សង្គត់សង្កិន ឃោឃៅ និង ផ្តាច់ការ ដល់ប្រជាពលរដ្ឋ នៅក្នុង ពិភពលោក។ ការគោរព នៃ គោលការណ៍ នៃ អធិបតេយ្យភាព នៃរដ្ឋលើសលាន់ វានឹងបន្តប់នូវសេរីភាពនៃពលរដ្ឋ ជាពុំខាន។ តែ សេរីភាព លើសលាន់ ជា ឆ្ពួតយស លើសលាន់ វានឹងបង្កើត នូវអយុត្តិធម៌សង្គម និង ការដាក ទៅរក សង្គម នៃពួកវរ:ជន ដែលជាប្រភព នៃ អំណាចផ្តាច់ការ នៃបញ្ហា, នៃមធ្យោបាយ, នៃវណ្ណ: ។ល។ ចំពោះ អ្នកឆ្វេងនិយមសព្វថ្ងៃ គេយល់ឃើញថា សង្គមសេរី ជា សង្គម នៅមានវណ្ណ:សង្គម ហើយ បញ្ហានេះ វា មិនអាច ដោះស្រាយបានជាដាច់ខាត នៅក្នុងក្របខណ្ឌ នៃ សេរីនិយម ឬ លទ្ធិប្រជាធិបតេយ្យសេរី ព្រោះ អ្នកសេរីនិយម គេយល់ឃើញថា មនុស្សលោក តាមធម្មជាតិ វាមិនស្មើគ្នា ឡើយ ; បើចាត់ថា ស្មើគ្នា វិញ គឺ មិនមែនជាការអះអាងនោះ ទេ ផ្ទុយទៅវិញ វាជា ការមិនទទួលស្គាល់ នៃធម្មជាតិ តែម្តង។

ដូច្នេះ គួរពិនិត្យ លើ វិសមភាព នៃសង្គម ដែលចែកជា ពីរ ប្រភេទ : ទី១ គឺ វាអាចទម្លាក់ទោស ទៅលើ ការកំណត់ នៃ មនុស្ស (convention humaine), ទី២ គឺ ធម្មជាតិ និង សេចក្ដី ត្រូវការចាំបាច់ ជាធម្មជាតិ របស់មនុស្ស។

វិបត្តិ នៃ លទ្ធិប្រជាធិបតេយ្យសេរី

ប្រភេទ ទី១ គឺនៅលើ ឧបសគ្គ ពេញច្បាប់ នឹង សមភាព : ការ បែកចែកសង្គម តាមអាជីពបិទទ្វារ, ច្បាប់ដាក់ព្រំដែន, សិទ្ធិ ឆ្នោះឆ្នោត មានលក្ខខណ្ឌ ។ល។ លើសពីនេះទៀត វាមាន ការ កំណត់វិសមភាព ពី វប្បធម៌ នៃ ក្រុមជាតិពិន្ទផ្សេងៗ និង សាសនា ប្រទល់នឹង ជីវិតភាពសេដ្ឋកិច្ច ។ល។

ចំណែក ឧបសគ្គ ជាធម្មជាតិ វិញ ចាប់ផ្តើមមានជាមួយ ការ ចែកមិនស្មើគ្នា នៃ សមត្ថភាព ឬ កេតនភណ្ឌ ជាធម្មជាតិ នៅ ក្នុង ប្រជាជន។ មនុស្ស មិនអាចទៅជា បណ្ឌិត ទាំងអស់គ្នា បានទេ, ស្ត្រី និង បុរស មិនអាចស្អាតដូចៗគ្នាទេ។ ជួនកាល គេ ទុក ឧបសគ្គ ជាធម្មជាតិ ភ្ជាប់នឹង អនុភាព នៃទីផ្សារ មូល ធននិយម ព្រោះវាភ្ជាប់នឹង ដំបន់, ប្រទេស ដែលវាមានធម្ម ជាតិ ខុសៗគ្នា ដែលអាចនឹងមាន ឥទ្ធិពល ដោយចំពោះ ទៅ លើ ការបង្កើតផល។

នៅគ្រប់សង្គមសេរី វាជួញចិត្ត តិចច្រើន ក្នុងការលប់បំបាត់ នៃប្រភព វិសមភាព ជាកំណត់ (inégalité conventionnelle)។ លើសពីនេះទៀត ភាពស្វាហាប់ នៃសេដ្ឋកិច្ច មូលធននិយម មាននិន្នាការ ទៅផ្តាប់ឧបសគ្គជាកំណត់ ជាច្រើន និង វប្បធម៌ ទៅរកវិសមភាព តាម ការបន្ត បំលាស់ប្តូរ ជានិច្ច នៃ ការផ្តល់ ជូនការងារ។ ជាការពិត មូលធមនិយម គឺជា កម្លាំងស្វាហាប់ ដែលវាយប្រហារតតណ្ឌ លើ គ្រប់ទំនាក់ទំនង សង្គម ជា កំណត់ សុទ្ធសាធ និង ជំនួស នូវ បុព្វសិទ្ធិ ពីកេ៍រ នឹង ស្រទាប់ថ្នី

វិបត្តិ នៃ លទ្ធិប្រជាធិបតេយ្យសេរី

សង្គម ផ្អែកលើមូលដ្ឋាន នូវ ការប្រសប់ និង ការអប់រំ។ បើ គ្មាន អក្ខរកម្ម និង សិក្សាធិការសាកល, គ្មាន សញ្ញាបត្រខ្ពស់ នៃ ចលាតសង្គម និង អាជីវកម្ម បើចំហ ដល់គ្រប់ទេពកោសល្យ ជាជាង ដល់បុព្វសិទ្ធិ, សង្គមមូលធននិយម មិនអាច មាន ដំណើរការបាន ឬ មាន ប្រសិទ្ធិភាព ដែលខ្លួនអាចធ្វើបាន។ ដូច្នេះ សង្គមសេរី និងមូលធននិយមវាពិតនៅមាន វិសមភាព ពី ភាពខុសគ្នា ជាធម្មជាតិ នៃទេពកោសល្យ និង ការបែង ចែក ដោយសេដ្ឋកិច្ច ជាការចាំបាច់ សំរាប់ តម្រូវការ នៃ ការងារ តែប៉ុណ្ណោះ។

តាម លោក Kojève គេអាចចាត់ទុកបាន ថា សហរដ្ឋអាមេរិក ពិតជាបាន សមិទ្ធិកម្ម នូវ ‹សង្គម គ្មានវណ្ណ:› របស់លោក Marx : គឺមិនមែនថា គ្រប់វិសមភាព ត្រូវបានរំលាយចោល អស់, តែ របាំង ដែលនៅមាន វាជា របៀបមួយយ៉ាង ជា ‹ការ ចាំបាច់ និង មិនអាចដកចេញបាន› ដោយសារតែធម្មជាតិ ជាង ឆន្ទ: នៃមនុស្សលោក។ លោក Tocqueville បានធ្វើការ សង្កេតដែរថា សេរីភាព និង សមភាព ជាមូលដ្ឋានកូនភ្លោះ នៃសង្គមសេរី ដែលវាតែងតែមានភាពតានតឹងដាក់គ្នា តែជា ‹ការចាំបាច់ និង មិនអាចដកចេញបាន› ព្រោះទំនាស់នេះវា កើតចេញមកពី វិសមភាព ជាធម្មជាតិ។ គ្រប់ ការប្រឹងប្រែង ដើម្បី ផ្តល់អោយ អ្នកទន់ខ្សោយ នូវ ‹សក្តិយស ស្មើគ្នា› តែងតែ ធ្វើអោយអន់ថយ នូវ សេរីភាព ឬ សិទ្ធិ ដល់ អ្នកប្រភេទផ្សេង ទៀត។

វិបត្តិ នៃ លទ្ធិប្រជាធិបតេយ្យសេរី

ការរីកចំរើន នៃមនុស្សជាតិ វាមានដោយសារតែ ‹ចំណង់ឲគេទទួលស្គាល់ខ្លួន› ជា ជនបរវ ដែល ជាចំណង់ ដែលត្រូវតែមានកុំឲតែ វាក្លាយទៅជា ឆ្លួតលើសលាន់ ព្រោះបើនៅក្នុងសង្គម វាគ្មាន មនុស្សមាន ចំណង់នេះ គឺច្បាស់ជាសង្គមនោះ ដឹកនាំដោយ ពួកអ្នកគ្មានសមត្ថភាព ជាពុំខាន ; ជាសង្គមគ្មានអ្វីស្មើ នៅក្នុងសក្តានុពល សេដ្ឋកិច្ច ; ធ្ងន់ធ្ងរបន្ថែមទៀត គឺ ជាសង្គម គ្មានសម្ថភាពនឹងការពារ នូវអារ្យធម៌ នៃខ្លួនតែម្តង។

ដូច្នេះ ការស្វែងរក នៃ គុណសម្បត្តិ ល្អជាង របស់បុគ្គល ឬ ពលរដ្ឋម្នាក់ៗ វាជាការចាំបាច់មួយ សំរាប់ការពារ លទ្ធិប្រជាធិបតេយ្យសេរី ដ្បិត លទ្ធិនេះ វាត្រូវការ ‹ឆ្លួតយស› ក្នុងកំរិតមួយ ដើម្បី ឲមាននៅក្នុងសង្គម នូវ គំនិត នៃ ការចាប់ផ្តើមធ្វើ (esprit d’entreprise) ដែលនាំបង្កើត នូវភាពសម្បូណ៌ នៅក្នុងសង្គម។ ដូច្នេះ គេអាចហៅបានថា ឆ្លួតយសវិជ្ជមាន សំរាប់សង្គម គឺជា ការប្រកួត ដើម្បី លុះភាពជា ជនបរវ។ នៅត្រង់ចំណុចនេះឯង ដែលជា ភាពខុសគ្នាស្រឡះ នៃ សង្គមសេរី នឹងសង្គមកុម្មុយនិស្ត។ បរាជ័យ នៃ គំរោង ម៉ារ្សនិយម (marxiste) គឺ ស្វែងរក ប្រតិបត្ត នូវទម្រង់ នៃ សមភាពសង្គម ជ្រុលហួសហេតុ ដែលនាំបំផ្លាញ នូវសេរីភាព តាមវិធី រំលាយ វិសមភាពជាធម្មជាតិ ដោយចែកជា រង្វាន់ នៃសេចក្ដីត្រូវការ (rétribution des besoins) និង អនេពាកោសល្យ តាម ការរំលាយ នៃ ការបែងចែក នៃការងារ។ អង្គការលើខ្សែក្រហម សាកល្បង នូវគំរោងនេះ ថែមទាំង បំបាត់ចោលអោយសូន្យ នូវភាព ខុសគ្នា

រវាង ការហត្ថកម្ម និង ការបញ្ជាកម្ម ដោយ ដកហូត សិទ្ធិ ទាំងអស់ពីប្រជាជនដែលនាំអោយសង្គមខ្មែរក្លាយជាសង្គម អវិជ្ជា។ បរាជ័យ នៃកំរោង ម៉ារ្សនិយម នេះ ក្រោយមក ត្រូវពួកសូវៀតគេកែតម្រូវ អោយមាន វិសមភាពខ្លះ ដែលលោក Milovan Djilas ហៅថា ‹វណ្ណ:ថ្មី› ជាផ្លូវការ នៃ បក្សកុម្មុយនិស្ត។

តែ ជ័យជំនះ លទ្ធិប្រជាធិបតេយ្យសេរី លើ លទ្ធិកុម្មុយនិស្ត វាចាប់ផ្តើមស្រពោន ព្រោះនៅក្នុង បរិបទ នយោបាយ និង សេដ្ឋកិច្ច ថ្មី ក្នុងពិភពលោក នាំអោយសហរដ្ឋអាមេរីក និង លោកខាងលិច ដែលជាប្រទេសប្រជាធិបតេយ្យលុះមុខ រើសយកជំហរ នូវ ការពារខ្លួន ក្នុងនាម នយោបាយប្រកដនិយម (realpolitik) នៅចំពោះមុខ ចិនប្រជាមានិត និង សហភាពរ៉ូស្ស៊ី ដែលជា ប្រទេស មានប្រព័ន្ធដឹកនាំផ្តាច់ការ តែមានកម្លាំងសេដ្ឋកិច្ចរៃលុក នៅក្នុងពិភពលោក ជាពិសេស ប្រទេសចិន។ ប្រទេស ទាំងពីរនេះ ទាមទារ សិទ្ធិ ខុសគ្នា នៅចំពោះមុខ បទដ្ឋាន នៃលោកសេរី ក្នុង វិស័យ សិទ្ធិមនុស្ស, លទ្ធិប្រជាធិបតេយ្យ និង សីលធម៌។ មិនតែប៉ុណ្ណោះ ថែមទាំងផ្តល់ នូវការគាំទ្រនយោបាយ និង ជំនួយសេដ្ឋកិច្ច ដល់ពួកអ្នកដឹកនាំផ្តាច់ការ នៅក្នុងពិភពលោក ដែលនាំអោយជនទាំងឡាយនោះ ធ្វើនយោបាយ សង្កត់សង្កិន យ៉ាងឃោឃៅបំផុត ទៅលើប្រជាជនដើម្បី រក្សាអំណាច។ វាហាក់បីដូចជាមាន ដំណើរដើរថយក្រោយយ៉ាងរហ័ស នៃលទ្ធិប្រជាធិបតេយ្យសេរី នៅក្នុងប្រទេស ជាច្រើននៅក្នុងពិភពលោក ហើយ ប្រទល់នឹង ការថយនេះ ពួក

វិបត្តិ នៃ លទ្ធិប្រជាធិបតេយ្យសេរី

ប្រទេសប្រជាធិបតេយ្យលុះមុខ មានឥរិយាបថ ធ្ងរលុង រហូតជួនកាល ថែមទាំង គាំទ្រ ដើម្បី រកប្រយោជន៍ ធ្វើអោយ ជនផ្តាច់ការ ក្លាយជា មនុស្ស ឆ្លួតយស លើសលាន់ ដែលពាក្យខ្មែរ ហៅថា ‹មានតែអញ› គឺថា ‹អញរស់ ឯងស្លាប់›។

ទុព្វលភាព នៃលទ្ធិប្រជាធិបតេយ្យសេរី នៅចំពោះមុខ ឆ្លួតយស លើសលាន់ នេះ វានាំបង្កើតវិបត្តិ នៃតម្លៃលទ្ធិ ដូច លទ្ធិកុម្មុយនិស្ត បានជួបប្រទះ រួចមកហើយ ដែលនាំអោយ រលាយខ្លួន។ សួរថា តើ ការណ៍នេះ វានឹងអាចជា អនាគត នៃលទ្ធិប្រជាធិបតេយ្យសេរី ? ចំពោះ សហរដ្ឋអាមេរិក ចម្លើយ គឺ ‹ទេ›, ចំពោះ អឺរ៉ុប ចម្លើយ គឺ ‹ទេ មិនច្បាស់› តែចំពោះប្រទេសទន់ខ្សោយវិញ ដូចយ៉ាង នៅ អាហ្វ្រិក, អាមេរិកឡាទិន, អាស៊ី ដូចយ៉ាង ស្រុកខ្មែរ ចម្លើយ គឺ ‹មែន›។ ត្រូវដឹងថា លទ្ធិប្រជាធិបតេយ្យសេរី ធ្លាប់រលាយខ្លួនម្តងហើយនៅ ប្រទេស អាឡឺម៉ាញ មកពីខ្លួន មានទុព្វលភាព ប្រទល់នឹង លទ្ធិណាស៊ី ដែលបង្កើតឡើងដោយ ជនឆ្លួតយស លើសលាន់ ឈ្មោះ Hitler ដែលជា កត្តានាំបង្កើតសង្គ្រាមលោកលើកទី២។ នៅប្រទេសបារាំង នៅពេលសង្គ្រាមនោះ លទ្ធិប្រជាធិបតេយ្យសេរី ត្រូវបានជំនួសដោយ លទ្ធិផ្តាច់ការ ហៅថា របបវីស៊ី ឬ ប៉េតាំង។ អ្វីដែលធ្លាប់កើតមាន វានឹងអាចកើតឡើងជាថ្មីម្តងទៀត។ ត្រូវដឹងថា នៅស្រុកខ្មែរ លទ្ធិប្រជាធិបតេយ្យសេរី ដែលបង្កើតឡើងដោយ អង្គការសហប្រជាជាតិ អាចរលាយបាន។ ការណ៍នេះហើយ ដែលជា វិបត្តិ នៃលទ្ធិប្រជាធិបតេយ្យសេរី៖